**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ១៤២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក. ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយដែលមានឈ្មោះថា «វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ» ឈ្មោះជាភាសាអង់គ្លេស «Kirirom Institute of Technology» សរសេរកាត់ជាភាសាខ្មែរ «វបគ» និងសរសេរកាត់ជាភាសាអង់គ្លេស « KIT »។

**មាត្រា ២.-**

វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ មានទីតាំងស្ថិតនៅក្នុងឧទ្យានជាតិព្រះសុរាម្រិត(គីរីរម្យ) ឃុំត្រែងត្រយឹង ដែលស្ថិតក្នុងការគ្រប់គ្រងរដ្ឋបាលនៃឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៣.-**

វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ លើ ៤ដេប៉ាតឺម៉ង់ មាន ៤មុខជំនាញដូចខាងក្រោម៖

| | |
|---|---|
| ១-ដេប៉ាតឺម៉ង់វិស្វកម្ម៖ | មុខជំនាញវិស្វកម្មកុំព្យូទ័រ |
| ២-ដេប៉ាតឺម៉ង់ស្ថាបត្យកម្ម៖ | មុខជំនាញប្លង់និងរចនា |
| ៣-ដេប៉ាតឺម៉ង់គ្រប់គ្រង៖ | មុខជំនាញគ្រប់គ្រងទេសចរណ៍ |
| ៤-ដេប៉ាតឺម៉ង់ភាសាបរទេស៖ | មុខជំនាញភាសាជប៉ុន |

ទៅអនាគតវិទ្យាស្ថាននេះ អាចបើកសាខា មហាវិទ្យាល័យថ្មី ដេប៉ាតឺម៉ង់ថ្មី ឯកទេសថ្មី កម្រិត ឬថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី សុំប្តូរឈ្មោះថ្មី ឬទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៤.-**

វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៥.-**

នាយកវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ មានភារកិច្ច៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឱ្យចូលរៀនស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំផ្ទៃក្នុងនៅឧត្តមសិក្សា
- ធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាល រួចបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា ក្រោយដំណាច់ឆមាសទី២។

**មាត្រា ៦.-**

និស្សិតនៃវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ ដែលបានរៀនចប់កម្មវិធីសិក្សា និងទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយ

វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ បំពេញនិងអនុវត្តបានតាមគោលការណ៍និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អគ្គលេខាធិការគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងនាយកវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ស្ពឺ
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ